# ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា

# ជំពូក០៦

# តម្រូវការនានានៃការបោសសម្អាតមីន

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៨១| ០២៣-៨៨១-៤៩២
អ៊ីមែល: deth@cmaa.gov.kh
គេហទំព័រ: www.cmaa.gov.kh

## មាតិកា................................................................................................................ក


**សេចក្តីផ្តើម**.................................................................................................................១
**តម្រូវការនៃការបោសសម្អាតមីន**.......................................................................................២
**១. ទ្រង់ទ្រាយ**..................................................................................................................២
**២. វាក្យសព្ទនិងនិយមន័យ**.................................................................................................២
**៣. តម្រូវការជាក់លាក់សំរាប់ការបោសសម្អាតមីន**....................................................................២
**៤. ការធ្វើផែនការបោសសម្អាតមីន**......................................................................................៣
៤.១ សុពលភាពនៃភារកិច្ចបោសសម្អាត និង ការជ្រើសរើសភារកិច្ច.............................................៣
៤.២ ការធ្វើផែនការការងារបោសសម្អាត...................................................................................៣
**៥. ការទំនាក់ទំនងសហគមន៍**...............................................................................................៣
**៦. គុណភាពនៃការបោសសម្អាត**............................................................................................៤
**៧. កិច្ចសន្យានិងកិច្ចព្រមព្រៀងបោសសម្អាត**..........................................................................៤
**៨. ការទទួលខុសត្រូវនិងភាតព្វកិច្ច**......................................................................................៥
៨.១. ការទទួលខុសត្រូវរបស់អាជ្ញាធរមីន.................................................................................៥
៨.២. ការទទួលខុសត្រូវរបស់ប្រតិបត្តិករ....................................................................................៥
៨.៣. ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយ...................................................................................៦
៨.៤. ការទទួលខុសត្រូវរបស់អតិថិជន........................................................................................៦

## សេចក្ដីផ្ដើម

គោលដៅនៃការងារបោសសម្អាតមីននៅកម្ពុជា គឺជាការកំណត់អត្តសញ្ញាណ និងការយកចេញ ឬការបំផ្លាញចោលនូវគ្រាប់មីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងអស់ ពីតំបន់ជាក់លាក់ណាមួយឲ្យបានដល់ជម្រៅ និងគុណភាពដែលបានកំណត់។ ផ្ទៃដីនិងជម្រៅដែលត្រូវបោសសម្អាតមីន ត្រូវសំរេចដោយការសិក្សាវាយតំលៃលើការប្រើប្រាស់ដីក្រោយពេលបោសសម្អាតមីនរួច ការស្រាវជ្រាវបច្ចេកទេស ឬព័ត៌មានដែលអាចទុកចិត្តបាន អាចកំណត់វិសាលភាពនៃតំបន់ និងជម្រៅនៃការគ្រោះថ្នាក់ដោយសារមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

ការសិក្សាវាយតម្លៃលើតម្រូវការបោសសម្អាតមីន សំដៅធានាថាភារកិច្ចដ៏សមរម្យត្រូវបានជ្រើសរើសសម្រាប់កិច្ចប្រតិបត្តិការបោសសម្អាតមីន ការប្រើប្រាស់ដីក្រោយពេលបោសសម្អាតមីនរួច និងអ្នកទទួលផល ត្រូវបានកំណត់កម្រិតគ្រោះថ្នាក់ពិតប្រាកដ ព័ត៌មានបច្ចេកទេស និងវិសាលភាពនៃការងារត្រូវបានបញ្ជាក់ ព្រមទាំងកត់ត្រាច្បាស់លាស់ ហើយដំណើរការគ្រប់គ្រងគុណភាព និងប្រសិទ្ធភាពនៃការបោសសម្អាតមីនត្រូវបានអនុវត្ត។

អ្នកទទួលផលពីកម្មវិធីបោសសម្អាតមីនផ្នែកមនុស្សធម៌ ត្រូវតែទទួលបានការជឿទុកចិត្តថា ដីដែលបានបោសសម្អាតមីនរួច មានសុវត្ថិភាពសំរាប់ការប្រើប្រាស់របស់ខ្លួន។ ចំណុចនេះ ទាមទារអោយមានប្រព័ន្ធគ្រប់គ្រងនីតិវិធីបោសសម្អាតមីន និងដំណើរការគ្រប់គ្រងគុណភាពដោយបានចងក្រងជាឯកសារច្បាស់លាស់ មានលក្ខណៈសមស្របប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។ គោលបំណងនៃការប្រើប្រាស់ដីបោសសម្អាតមីនរួច ត្រូវបានរៀបចំឡើងតាមរយៈការពិគ្រោះយោបល់ជាមួយសហគមន៍ទទួលផល និងគណៈកម្មាធិការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន។ សហគមន៍មូលដ្ឋាន គួរទទួលបាននូវការពន្យល់សង្ខេបជារឿយៗក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការបោសសម្អាតមីនពីប្រតិបត្តិករដោះមីន ដែលសកម្មភាពនេះ គឺជាវិធានការណ៍នៃការកសាងទំនុកចិត្តប្រកបដោយប្រសិទ្ធភាព។ ការទំនាក់ទំនងសហគមន៍ គឺជាផ្នែកមួយនៃសមាហរណកម្មដំណើរការបោសសម្អាតមីន ហើយអាចសម្រេចបានតាមរយៈសេវាកម្មនៃក្រុមការងារអប់រំយល់ដឹងពីគ្រោះថ្នាក់មីន ឬតាមរយៈសមាជិកនៃប្រតិបត្តិករបោសសម្អាតមីនដែលបានបណ្ដុះបណ្ដាលត្រឹមត្រូវ។ ការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការបោសសម្អាតមីន គឺជាសកម្មភាពមួយដែលត្រូវបានត្រួតពិនិត្យ និងកត់ត្រាទុក ដែលជាផ្នែកមួយនៃដំណើរការគ្រប់គ្រងគុណភាព។

ការគ្រប់គ្រងគុណភាពពីផ្នែកខាងក្រៅនៃសកម្មភាពកម្ចាត់មីននៅក្នុងប្រទេសកម្ពុជា រួមមានការផ្ដល់ប័ណ្ណទទួលស្គាល់ការផ្ដល់អាជ្ញាប័ណ្ណ និងការត្រួតពិនិត្យទៅលើប្រតិបត្តិករបោសសម្អាតមីននៅមុន និងក្នុងអំឡុងពេលនៃដំណើរការបោសសម្អាតមីន ហើយអាជ្ញាធរមីនក៏ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងគុណភាពផ្ទៃក្នុងរបស់ប្រតិបត្តិករបោសសម្អាតមីនផងដែរ។ ដើម្បីសម្រេចបាននូវគោលដៅនេះ បណ្ដាប្រតិបត្តិករបោសសម្អាតមីនត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងមួយប្រកបដោយប្រសិទ្ធភាពដើម្បីបង្កើត និងថែរក្សានីតិវិធី ក្នុងការដាក់ឲ្យអនុវត្តប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។ នីតិវិធីនៃការគ្រប់គ្រងត្រូវតែមានតម្លាភាព និងអាចធ្វើសវនកម្មបាន។ គោលបំណងនៃដំណើរការគ្រប់គ្រងគុណភាព គឺដើម្បីអោយអាជ្ញាធរមីនអាចទទួលបាននូវកំរិតនៃការទុកចិត្តលើដីដែលបានបោសសម្អាតមីនរួច ថាមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

គុណភាពនៃការបោសសម្អាតមីន ត្រូវតែអាចទទួលយកបានទាំងអាជ្ញាធរមីន និងសហគមន៍មូលដ្ឋានដែលទទួលផល ព្រមទាំងអាចវាស់វែង ផ្ទៀងផ្ទាត់ និងបានកត់ត្រាជាក់លាក់។ ដំណើរការរួមគ្នានៃការកំណត់អត្តសញ្ញាណលើតម្រូវការនៃការប្រើប្រាស់ដី និងការគ្រប់គ្រងគុណភាពនៃការងារបោសសម្អាតមីននឹងជួយក្នុងការទទួលបាននូវកម្រិតនៃការជឿជាក់ដែលអាចទទួលយកបានថា ដីនោះត្រូវបានបោសសម្អាត ដោយអនុលោមតាមកម្រិតស្តង់ដាខ្ពស់ និងមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

# តម្រូវការនៃការបោសសម្អាតមីន

## ១. ទ្រង់ទ្រាយ

ស្តង់ដានេះកំណត់អត្ថន័យនៃពាក្យ"បោសសម្អាត" និងតម្រូវការនៃការបោសសម្អាតសំរាប់កិច្ចប្រតិបត្តិការបោសសម្អាតមីន។ តម្រូវការនៃការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម មានចែងនៅក្នុងស្តង់ដាជំពូក០៧។ ស្តង់ដានេះក៏បានចែងពីដំណើរការ ដើម្បីធានាថាដីដែលបានកំណត់សំរាប់ធ្វើការបោសសម្អាត ត្រូវបានជ្រើសរើសដោយហ្មត់ចត់ ហើយវិធីសាស្ត្រនៃការបោសសម្អាត មានភាពសមស្របទៅនឹងកម្រិតនៃការគម្រាមកំហែងដែលបានដឹង និងគម្រោងប្រើប្រាស់ដី ជាមួយនេះផងដែរគុណភាពនៃការបោសសម្អាតមីន ក៏ផ្តល់នូវទំនុកចិត្តខ្ពស់ដល់អ្នកទទួលផល អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា។

## ២. វាក្យសព្ទ័និងនិយមន័យ

សទ្ទានុក្រម និងនិយមន័យដែលបានប្រើប្រាស់នៅក្នុងស្តង់ដានេះ មានចែងនៅក្នុងស្តង់ដាជំពូក៣០។

## ៣. តម្រូវការជាក់លាក់សំរាប់ការបោសសម្អាតមីន

ដីដែលត្រូវបានទទួលស្គាល់ថា "បោសសម្អាតរួច" នៅពេលដែលប្រតិបត្តិករបោសសម្អាតមីន អះអាងថាការយកចេញ និង/ឬ ការបំផ្លាញចោលគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមគ្រប់ប្រភេទ ពីតំបន់តាមជម្រៅដែលបានកំណត់ជាក់លាក់នៅក្នុងកិច្ចសន្យា/កិច្ចព្រមព្រៀងបោសសម្អាតមីន ឬនៅក្នុងផែនការ និងរាល់ដំណើរការគ្រប់គ្រងគុណភាពត្រូវបានអនុវត្ត និងកត់ត្រាពេញលេញ។

ផ្ទៃដីជាក់លាក់ដែលត្រូវបោសសម្អាត ត្រូវកំណត់ដោយការស្រាវជ្រាវបច្ចេកទេស និងការសិក្សាវាយតំលៃលើការប្រើប្រាស់ដីក្រោយពេលបោសសម្អាតមីនរួច។ ជម្រៅជាក់លាក់ដែលត្រូវបោសសម្អាតមីន ត្រូវកំណត់ដោយការស្រាវជ្រាវបច្ចេកទេសឬព័ត៌មានដែលអាចទុកចិត្តបានដែលអាចកំណត់វិសាលភាពនៃតំបន់ និងជម្រៅគម្រាមកំហែងដោយសារមីននិងការវាយតំលៃលើគោលបំណងនៃការប្រើប្រាស់ដី ប៉ុន្តែត្រូវមានជម្រៅអប្បបរិមា ១៣ សង់ទីម៉ែត្រ សម្រាប់មីនប្រឆាំងមនុស្ស និង ៣០ សង់ទីម៉ែត្រ សម្រាប់មីនប្រឆាំងរថក្រោះ។ ការកំណត់ជម្រៅសម្រាប់បោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាមគួរគិតដល់កម្រិតគម្រាមកំហែងនិងគោលបំណងប្រើប្រាស់ដី។ ក្នុងករណីពុំមានព័ត៌មានដែលអាចទុកចិត្តបានស្តីពីជម្រៅមីននៅក្នុងតំបន់គ្រោះថ្នាក់នៅមូលដ្ឋាន តម្រូវការខាងក្រោមនេះត្រូវយកមកអនុវត្ត។

**ចំណាំ១:** មីនកប់ក្នុងដីជម្រៅអប្បបរិមា ១៣ ស.ម សម្រាប់មីនប្រឆាំងមនុស្ស និង ៣០ ស.ម សម្រាប់មីនប្រឆាំងរថក្រោះ ដោយវាស់ពីផ្ទៃដីសើលើទៅត្រឹមកំពូលគ្រាប់មីន។

**ចំណាំ២:** បើសិនមានការស្រាវជ្រាវមិនបច្ចេកទេសឬការស្រាវជ្រាវបច្ចេកទេស ឬគោលបំណងនៃការប្រើប្រាស់ដីតម្រូវអោយមានការបោសសម្អាតជ្រៅជាង ១៣ ស.ម សំរាប់មីនប្រឆាំងមនុស្ស និង ៣០ ស.ម សម្រាប់មីនប្រឆាំងរថក្រោះ នោះវិធីសាស្ត្រសម្រាប់បោសសម្អាតសមស្របមួយគួរត្រូវបានអនុវត្ត។

**ចំណាំ៣:**

ប្រតិបត្តិករបោសសម្អាតមីនត្រូវធានាថាឧបករណ៍ដែលយកមកប្រើប្រាស់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរាវរកទៅតាមជម្រៅនៃការបោសសម្អាតដែលតម្រូវនៅប្រទេសកម្ពុជា។ ម៉ាស៊ីនរាវរកមីនទាំងអស់ត្រូវតែធ្វើការសាកល្បង និងកត់ត្រាប្រចាំថ្ងៃ ដើម្បីធានាថា ម៉ាស៊ីនទាំងនោះអាចរាវទៅតាមជម្រៅកំណត់។

## ៤. ការធ្វើផែនការបោសសម្អាតមីន

ដំណើរការនៃការធ្វើផែនការបោសសម្អាតមីន សំដៅធានាថាភារកិច្ចដ៏សមរម្យមួយត្រូវបានជ្រើសរើសសម្រាប់កិច្ចប្រតិបត្តិការបោសសម្អាតមីន ដែលការប្រើប្រាស់ដីក្រោយពេលបោសសម្អាតមីនរួច និងអ្នកទទួលផលត្រូវបានកំណត់កំរិតគម្រាមកំហែងពិតប្រាកដ ព័ត៌មានបច្ចេកទេស និងវិសាលភាពនៃការងារត្រូវបានបញ្ជាក់ព្រមទាំងកត់ត្រាច្បាស់លាស់ ហើយដំណើរការគ្រប់គ្រងគុណភាព និងប្រសិទ្ធភាពនៃការបោសសម្អាតមីន ត្រូវបានអនុវត្ត។

### ៤.១ សុពលភាពនៃភារកិច្ចបោសសម្អាត និង ការជ្រើសរើសភារកិច្ច

ចាំបាច់ត្រូវធានាថា ដីដែលបានបោសសម្អាតរួចសមស្របទៅតាមការចាត់ជាអាទិភាពថ្នាក់ជាតិ និងខេត្ត និងមានផលវិជ្ជមានដល់សេដ្ឋកិច្ច-សង្គមទៅលើសហគមន៍មូលដ្ឋាន។ ការវាយតំលៃក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍ដែលទទួលផល គណៈកម្មាធិការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង និងក្រុមការងារផែនការសកម្មភាពកម្ចាត់មីនត្រូវអនុវត្តដើម្បីធានាថាដីដែលបានបោសសម្អាតរួច ត្រូវបានប្រើប្រាស់ប្រកបដោយមានប្រសិទ្ធភាពត្រឹមត្រូវ និងមាននិរន្តរភាព ហើយការប្រើប្រាស់ដីក្រោយការបោសសម្អាតរួច ត្រូវបានកំណត់យ៉ាងច្បាស់លាស់។

### ៤.២ ការធ្វើផែនការការងារបោសសម្អាត

ការស្រាវជ្រាវបច្ចេកទេស គួរផ្តល់នូវព័ត៌មានបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធ្វើអោយការបោសសម្អាតមានប្រសិទ្ធភាព និងសុវត្ថិភាព ឬការផ្ទៀងផ្ទាត់តំបន់ទាំងនោះត្រូវបានបញ្ជាក់។ ព័ត៌មានជាក់លាក់ផ្សេងទៀតដូចជាប្រភេទ និងជម្រៅគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ស្ថានភាពភូមិសាស្ត្រ លក្ខណៈដី ជាពិសេសដីដែលមានជាតិដែក កម្ទេចអំបែងដែក និងកំរិតព្រៃ/ស្មៅ ដែលជាកត្តាសំខាន់សំរាប់អ្នកគ្រប់គ្រងធ្វើការពិចារណារៀបចំផែនការបោសសម្អាត។

ក្នុងអំឡុងពេលធ្វើផែនការបោសសម្អាត ប្រធានប្រតិបត្តិការត្រូវយល់អោយបានច្បាស់អំពីការប្រើប្រាស់ដីក្រោយការបោសសម្អាតនិងតម្រូវការនៃជម្រៅសម្រាប់ធ្វើការបោសសម្អាត។ តម្រូវការនៃការបោសសម្អាត ត្រូវផ្អែកការសិក្សាវាយតំលៃពីការប្រើប្រាស់ដីក្រោយពេលបោសសម្អាត និងកម្រិតគម្រាមកំហែង ជម្រៅគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ផែនការបោសសម្អាត ត្រូវមានវិធីសាស្ត្រនៃការបោសសម្អាត និងការផ្ទៀងផ្ទាត់ដែលត្រូវអនុវត្តតាមផ្នែកនីមួយៗនៃការងារ ដែលអាចមានកម្រិតគ្រោះថ្នាក់ និងតម្រូវការនៃជម្រៅដែលត្រូវបោសសម្អាតផ្សេងៗគ្នា។

ការងារបោសសម្អាតខ្លះ អាចអនុវត្តមុនពេលការស្រាវជ្រាវបច្ចេកទេសត្រូវបានធ្វើឡើង។ ក្នុងករណីនេះ ប្រតិបត្តិករបោសសម្អាតមីន ត្រូវប្រមូលព័ត៌មានបច្ចេកទេសក្នុងពេលអនុវត្តដំណើរការបោសសម្អាត និងធ្វើការកែតម្រូវវិធីសាស្ត្របោសសម្អាត ដំណើរការ និងជម្រៅ តាមរយៈព័ត៌មានទទួលបាន។ ដំណើរការនេះ ត្រូវធ្វើការកត់ត្រាអោយមានសុក្រឹត្យភាព។

## ៥. ការទំនាក់ទំនងសហគមន៍

អ្នកទទួលផលពីកម្មវិធីបោសសម្អាត ត្រូវមានទំនុកចិត្តថា ដីដែលបានបោសសម្អាតរួច មានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។ ការចូលរួមរបស់សហគមន៍ក្នុងការកំណត់ផលប៉ះពាល់ និងផលប្រយោជន៍នៃការប្រើ

ប្រាស់ដីត្រូវបានអនុវត្តតាមរយៈការពិគ្រោះយោបល់ជាមួយ អ្នកទទួលផល សហគមន៍ គណៈកម្មាធិការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីន និងភ្នាក់ងារអភិវឌ្ឍន៍នានា។

សហគមន៍មូលដ្ឋានគួរទទួលបានព័ត៌មានអំពីសកម្មភាព និងដំណើរការវិវឌ្ឍន៍នៃការបោសសម្អាតតាមរយៈការផ្តល់ព័ត៌មាននិងការពន្យល់ជាប្រចាំពីប្រតិបត្តិករបោសសម្អាតមីនក្នុងអំឡុងពេលប្រតិបត្តិការផងដែរ។ ការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការបោសសម្អាតគឺជាសកម្មភាពមួយត្រូវបានត្រួតពិនិត្យ ដែលជាផ្នែកមួយនៃដំណើរការគ្រប់គ្រងគុណភាព។ ប្រសិនបើសហគមន៍មិនពេញចិត្តដំណើរការបោសសម្អាតបញ្ហានោះ នឹងត្រូវបញ្ជូនអោយក្រុមការងារផែនការសកម្មភាពកម្ចាត់មីនដោះស្រាយ។

## ៦. គុណភាពនៃការបោសសម្អាត

គុណភាពនៃការបោសសម្អាតមីនត្រូវបានធានាដោយ:

ក) ជ្រើសយកប្រតិបត្តិករបោសសម្អាតណាដែលមានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណត្រឹមត្រូវ

ខ) ការប្រើប្រាស់ឧបករណ៍ដែលស្របទៅតាមតម្រូវការបោសសម្អាត និងធានាថារាល់ម៉ាស៊ីនរាវមីនត្រូវបានធ្វើការសាកល្បង និងកត់ត្រាទុកជាប្រចាំ។

គ) ការធ្វើផែនការដែលមានប្រសិទ្ធភាពសម្រាប់ការងារបោសសម្អាត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបច្ចេកទេស និងតម្រូវការនៃជម្រៅបោសសម្អាតដែលបានកំណត់។

ឃ) ប្រើប្រាស់របៀបគ្រប់គ្រងជាក់ស្តែង និងអនុវត្តច្បាប់សុវត្ថិភាព នីតិវិធីប្រតិបត្តិការ ដែលមានលក្ខណៈសមស្រប និងមានប្រសិទ្ធភាព។

ង) ការគ្រប់គ្រងគុណភាពផ្ទៃក្នុង ការត្រួតពិនិត្យ និងការកត់ត្រាដោយប្រតិបត្តិករបោសសម្អាតមីន និងអង្គភាពចំណុះ

ច) ការគ្រប់គ្រងគុណភាព និងការត្រួតពិនិត្យផ្នែកខាងក្រៅ ដោយអាជ្ញាធរមីន។

ឆ) ការធ្វើការត្រួតពិនិត្យដីក្រោយការបោសសម្អាត ដោយអនុលោមតាមស្តង់ដាជំពូក ០៣។

## ៧. កិច្ចសន្យានិងកិច្ចព្រមព្រៀងបោសសម្អាត

កិច្ចសន្យានិង/ឬកិច្ចព្រមព្រៀងបោសសម្អាតគួរតែព្រាងបន្ទាប់ពីការប្រើប្រាស់ដីក្រោយការបោសសម្អាតត្រូវបានកំណត់ អ្នកទទួលផលត្រូវបានគូសបញ្ជាក់ ហើយបើអាចបន្ទាប់ពីការស្រាវជ្រាវបច្ចេកទេសត្រូវបានធ្វើឡើង។ ការរៀបចំកិច្ចសន្យាឬកិច្ចព្រមព្រៀង គួរបញ្ជាក់ពីតំបន់និងជម្រៅដែលត្រូវបោសសម្អាតព្រមទាំងតម្រូវការសម្រាប់ធ្វើការត្រួតពិនិត្យដីក្រោយពេលបោសសម្អាត។ តម្រូវការទាំងនេះ គួរត្រូវបានគូសបញ្ជាក់នៅក្នុងការពិគ្រោះយោបល់ និងការយល់ព្រមជាមួយអាជ្ញាធរមីន ក្នុងអំឡុងពេលរៀបចំកិច្ចសន្យា ឬកិច្ចព្រមពៀង។

**ចំណាំ៤:** ជម្រៅនៃការបោសសម្អាត អាស្រ័យលើគោលបំណងប្រើប្រាស់ដីក៏ដូចជាកម្រិតការគម្រាមកំហែងនៃគ្រាប់មីននិងគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ នៅក្នុងតំបន់ដែលត្រូវបោសសម្អាត និងកត្តាបរិយាកាសផ្សេង ៗ។ ឧទាហរណ៍: ចលនាដីនៅក្នុងវាលភក់ មាត់ទន្លេ ឬតំបន់លិចទឹក អាចធ្វើអោយមីនដែលពីមុនកប់មិនលើសពី ១៣ ស.ម នោះ មានជម្រៅជ្រៅជាងមុន។

**ចំណាំ៥:** បើសភាពដីមានការប្រែប្រួលក្រោយពេលបោសសម្អាតមីនរួចកិច្ចព្រមព្រៀងត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ ដើម្បីធានាកុំអោយមានការយល់ច្រឡំលើតម្រូវការជម្រៅដែលត្រូវបោសសម្អាត។ ប្រសិនបើមីនត្រូវបានរកឃើញជ្រៅជាងជម្រៅដែលបានកំណត់នៅក្នុងកិច្ចសន្យានោះ និងក្រោយពីការពិគ្រោះយោបល់ជាមួយអាជ្ញាធរមីនរួច ត្រូវបង្កើនជម្រៅរាវរកថែមទៀត។

**ចំណាំ៦:** តម្រូវការនៃជម្រៅដែលត្រូវធ្វើការបោសសម្អាត អាចកែតម្រូវទៅតាមការវិវឌ្ឍន៍នៃការងារបោសសម្អាត និងត្រូវបញ្ជាក់ផងដែរនៅក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងបោសសម្អាត។ រាល់ការធ្វើវិសោធនកម្ម ត្រូវមានការពិគ្រោះយោបល់ និងឯកភាពពីអាជ្ញាធរមីន គណៈកម្មាធិការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីន និងប្រទេសផ្តល់ជំនួយបើចាំបាច់។ រាល់ការផ្លាស់ប្តូរនានាលើកិច្ចសន្យា ឬកិច្ចព្រមព្រៀងដើម ត្រូវកត់ត្រាទុកជាផ្លូវការ។

**ចំណាំ៧:** តម្រូវការនៃជម្រៅបោសសម្អាត ត្រូវធ្វើការពិនិត្យឡើងវិញ បើសិនជាផែនការប្រើប្រាស់ដី មានការផ្លាស់ប្តូរ។

## ៨. ភារកិច្ចទទួលខុសត្រូវនិងភារកិច្ច

### ៨.១. ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

ក) ផ្តល់ប្រឹក្សាលើស្តង់ដា និងគោលការណ៍ណែនាំសម្រាប់ការធានាគុណភាព និងការត្រួតពិនិត្យគុណភាពដែលត្រូវអនុវត្តចំពោះកិច្ចសន្យា និងកិច្ចព្រមពៀងបោសសម្អាតមីន។

ខ) ផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណដល់ប្រតិបត្តិករបោសសម្អាតមីន។

គ) ត្រួតពិនិត្យ និងកត់ត្រាទុកនូវរាល់សកម្មភាពបោសសម្អាតមីនរបស់ប្រតិបត្តិករបោសសម្អាតមីន។

ឃ) ថែរក្សាផែនទីដីដែលបានបោសសម្អាតរួចនិងដីដែលមិនទាន់បានបោសសម្អាត ដើម្បីបង្ហាញពីស្ថានភាពដីដែលមានមីន ឬតំបន់សង្ស័យនីមួយៗ។

ង) ត្រួតពិនិត្យប្រតិបត្តិករបោសសម្អាតមីន និងអង្គភាពចំណុះ ដោយអនុលោមតាមស្តង់ដាជំពូក ៣ និងទៅតាមតម្រូវការនៃកិច្ចសន្យា ឬ កិច្ចព្រមព្រៀងបោសសម្អាតដែលពាក់ព័ន្ធ។

ច) ថែរក្សា និងផ្តល់ដល់ភាគីពាក់ព័ន្ធតាមផ្លូវច្បាប់នូវឯកសារដែលបានចុះតាមដាន និងត្រួតពិនិត្យដីតាមការដ្ឋាន។

### ៨.២. ការទទួលខុសត្រូវរបស់ប្រតិបត្តិករ

ក) ទទួលបានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណសមស្របពីអាជ្ញាធរមីន ។

ខ) អនុវត្តនីតិវិធីបោសសម្អាតមីន អនុលោមតាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា និងបទដ្ឋានប្រតិបត្តិការរបស់ខ្លួន។

គ) ថែរក្សា និងរៀបចំអោយមានឯកសារបោសសម្អាតមីនឲ្យបានគ្រប់គ្រាន់ និងមានបញ្ជាក់ពីពេលវេលាដូចដែលបានកំណត់ដោយអាជ្ញាធរមីន។

ឃ) អនុវត្តការគ្រប់គ្រងជាក់ស្តែង និងនីតិវិធីប្រតិបត្តិការ សម្រាប់បោសសំអាតមីនទៅតាមតម្រូវការដែលបានកំណត់នៅក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀង។

### ៨.៣. ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយ

ភ្នាក់ងារម្ចាស់ជំនួយត្រូវទទួលខុសត្រូវក្នុងការធានាថា គម្រោងកម្មវិធីដែលបានផ្តល់ថវិកា ត្រូវបានចាត់ចែងយ៉ាងមានប្រសិទ្ធភាព និងសុវត្ថិភាព ដោយអនុលោមតាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា។ ម្ចាស់ជំនួយក៏ទទួលខុសត្រូវក្នុងការធានាថាគម្រោងដែលបាននឹងផ្តល់ថវិកានោះ ស្របទៅនឹងអាទិភាពជាតិ និងខេត្ត តាមរយៈអាជ្ញាធរមីន និងគណៈកម្មាធិការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីន។ ការទទួលខុសត្រូវនេះ រួមទាំងការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់លើការកំណត់គម្រោងបោសសម្អាត ការបង្កើតឯកសារកិច្ចព្រមព្រៀង និងធានាថាប្រតិបត្តិករបោសសម្អាតមីនដែលត្រូវជ្រើសរើសអោយអនុវត្តកិច្ចព្រមព្រៀងទាំងនោះ ត្រូវអនុវត្តតាមលក្ខណៈវិនិច្ឆ័យនៃប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ ព្រមទាំងស្តង់ដានានា ដែលចេញដោយអាជ្ញាធរមីន។

### ៨.៤ ការទទួលខុសត្រូវរបស់អតិថិជន

ក) ជ្រើសយកប្រតិបត្តិករបោសសម្អាតណាដែលមានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណត្រឹមត្រូវ។

ខ) ធានាក្នុងការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមីន លើតម្រូវការបោសសម្អាត។

គ) ធានាថារបាយការណ៍បោសសម្អាត និងលិខិតបញ្ជាក់នានាត្រូវបានបញ្ជូនមកអាជ្ញាធរមីនទាន់ពេល ដើម្បីកត់ត្រា និងរក្សាទុកក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិ។

ភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៤

**អគ្គលេខាធិការ**

**ព្រំ សុគមង្គល**